# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ**
លេខ : ......០០២...ក.ក.ជ

រាជធានីភ្នំពេញ, ថ្ងៃទី..០៣....ខែ..មករា..ឆ្នាំ២០១..៤

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារបច្ចេកទេសលើវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ

## ឧបនាយករដ្ឋមន្ត្រី
## ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៩/៨៦៦ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០០៨/១១៣៨ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៨ ស្តីពីការតែងតាំងសមាសភាពថ្នាក់ដឹកនាំនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- បានឃើញចំណារឯកភាពរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៣ លើសំណើសុំការអនុញ្ញាតបញ្ចូលក្រុមការងារគាំពារសង្គម ទៅក្នុងក្រុមការងារបច្ចេកទេស ស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ
- យោងតាមការចាំបាច់របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ។

## សម្រេច

**ប្រការ ១.-** បង្កើតក្រុមការងារបច្ចេកទេសស្តីពីគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ - អក្សរកាត់ "ក.គ.ស.អ" (Technical Working Group on Social Protection, Food Security and Nutrition "TWG-SP, FS&N") ដើម្បីធ្វើឱ្យវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ បានប្រសើរឡើងឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា២០១៥ បច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ នៃរាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា។

**ប្រការ ២.-** ក្រុមការងារ ក.គ.ស.អ ជាក្រុមការងារអន្តរស្ថាប័នរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ជាមួយនឹងស្ថាប័នដៃគូអភិវឌ្ឍលើវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ ក្រុមការងារ ក.គ.ស.អ មានសមាសភាពដូចខាងក្រោមនេះ÷

| | | | |
|---|---|---|---|
| ១ | ឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី | ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | ប្រធាន |
| ២ | នាយកអង្គការស្បៀងអាហារពិភពលោក ប្រចាំកម្ពុជាជាអ្នកសម្របសម្រួលភាគីដៃគូអភិវឌ្ឍលើវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ | | |
| ៣ | នាយកអង្គការយូនីសេហ្វ ប្រចាំកម្ពុជា ជាអ្នកសម្របសម្រួលភាគីដៃគូអភិវឌ្ឍលើវិស័យគាំពារសង្គម | | |
| ៤ | ឯកឧត្តម ងី ច័ន្ទ្រផល | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ | អនុប្រធាន |
| ៥ | ឯកឧត្តម វ័ន្ត វិរៈ | សមាជិកក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | សមាជិក |
| ៦ | ឯកឧត្តម លឹម ស៊ីដេនីន | រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ៧ | ឯកឧត្តម ហ៊ូ តាំងអេង | រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ៨ | ឯកឧត្តម ងី តាយី | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៩ | ឯកឧត្តម កាន់ ម៉ន | រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១០ | ឯកឧត្តម សួស គង់ | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១១ | ឯកឧត្តម យិន គីមស៊ាន | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១២ | ឯកឧត្តម ជូ យិនស៊ីម | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១៣ | ឯកឧត្តម អះម៉ាត់ យ៉ះយ៉ា | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន | សមាជិក |

| | | | |
|---|---|---|---|
| | | និងយុវនិតិសម្បទា | |
| ១៤ | ឯកឧត្តម យក់ ង៉ុយ | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៥ | ឯកឧត្តម ទី សុគន្ធ | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៦ | ឯកឧត្តម តន់ វ៉ាន់ថារ៉ា | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១៧ | ឯកឧត្តម ជា សំណាង | នាយកខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី និងជាអគ្គលេខាធិការ ភ.១ ផ.១ | សមាជិក |
| ១៨ | ឯកឧត្តម ឡៅ សុខារម្ម | អគ្គលេខាធិការនៃ ក.ក.ជ | សមាជិក |
| ១៩ | តំណាងគណៈកម្មាធិការជាតិគ្រោះមហន្តរាយ (NCDM) | | សមាជិក |
| ២០ | តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | សមាជិក |
| ២១ | តំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | | សមាជិក |
| ២២ | តំណាងសភាពាណិជ្ជកម្មកម្ពុជា | | សមាជិក |
| ២៣ | តំណាងប្រចាំប្រទេសអង្គការស្បៀងនិងកសិកម្មសហប្រជាជាតិ (FAO) | | សមាជិក |
| ២៤ | នាយកសម្របសម្រួលថ្នាក់ជាតិនៃអង្គការពលកម្មអន្តរជាតិ (ILO) ប្រចាំកម្ពុជា | | សមាជិក |
| ២៥ | តំណាងប្រចាំប្រទេសកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) | | សមាជិក |
| ២៦ | តំណាងប្រចាំប្រទេសអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌នៃសហប្រជាជាតិ (UNESCO) | | សមាជិក |
| ២៧ | តំណាងប្រចាំប្រទេសមូលនិធិសហប្រជាជាតិដើម្បីប្រជាជន (UNFPA) | | សមាជិក |
| ២៨ | តំណាងប្រចាំប្រទេសអង្គការសុខភាពពិភពលោក (WHO) | | សមាជិក |
| ២៩ | តំណាងប្រធានធនាគារពិភពលោកប្រចាំប្រទេស (World bank) | | សមាជិក |
| ៣០ | តំណាងប្រចាំប្រទេសបេសកកម្មទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) | | សមាជិក |
| ៣១ | តំណាងប្រចាំប្រទេសទីភ្នាក់ងារអាល្លឺម៉ង់សម្រាប់ការអភិវឌ្ឍអន្តរជាតិ(GiZ) | | សមាជិក |
| ៣២ | ប្រធានបេសកកម្មធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំកម្ពុជា (ADB) | | សមាជិក |
| ៣៣ | តំណាងនាយកសហប្រតិបត្តិការអភិវឌ្ឍន៍ នៃនាយកដ្ឋានកិច្ចការបរទេស និងជំនួញ ស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា | | សមាជិក |
| ៣៤ | លេខាទី ១ ប្រធានផ្នែកសហប្រតិបត្តិការ នៃប្រតិភូសហគមន៍អឺរ៉ុបប្រចាំកម្ពុជា | | សមាជិក |
| ៣៥ | តំណាងមូលនិធិសម្រាប់អភិវឌ្ឍន៍កសិកម្មប្រចាំកម្ពុជា | | សមាជិក |
| ៣៦ | នាយកប្រចាំប្រទេសអង្គការ CARE-Cambodia | | សមាជិក |
| ៣៧ | នាយកប្រចាំប្រទេសអង្គការ Oxfam | | សមាជិក |

| | | | |
|---|---|---|---|
| ៣៨ | នាយកប្រចាំប្រទេសអង្គការ Plan-Cambodian | | សមាជិក |
| ៣៩ | នាយកប្រចាំប្រទេសអង្គការ Save the Children | | សមាជិក |
| ៤០ | នាយកប្រចាំប្រទេសអង្គការ World Vision-Cambodia | | សមាជិក |
| ៤១ | នាយកប្រតិបត្តិអង្គការ NGO-Forum | | សមាជិក |
| ៤២ | នាយកប្រចាំប្រទេសអង្គការ Hellen Keller International (HKI) | | សមាជិក |
| ៤៣ | នាយកប្រចាំប្រទេសអង្គការ Caritas-Cambodia | | សមាជិក |
| ៤៤ | នាយកប្រចាំប្រទេសអង្គការ RACHA | | សមាជិក |
| ៤៥ | ឯកឧត្តម សុខ ស៊ីឡូ | អគ្គលេខាធិការរងនៃ ក.ក.ជ និងជាប្រធានអង្គភាពសម្របសម្រួលវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ | សមាជិក |
| ៤៦ | ឯកឧត្តម សាន វឌ្ឍនា | អគ្គលេខាធិការរងនៃ ក.ក.ជ និងជាប្រធានអង្គភាពសម្របសម្រួលវិស័យគាំពារសង្គម | សមាជិក |
| ៤៧ | ឯកឧត្តម គាត រស្មី | ទីប្រឹក្សា ក.ក.ជ | សមាជិក |
| ៤៨ | ឯកឧត្តម តួច ប៊ុនហួរ | អគ្គលេខាធិការរងនៃ ក.ក.ជ | សមាជិក |
| ៤៩ | ឯកឧត្តម ហាស់ ម៉េងហុង | អគ្គលេខាធិការរងនៃ ក.ក.ជ | សមាជិក |
| ៥០ | ឯកឧត្តម ឡាំ អេងហួ | អគ្គលេខាធិការរងនៃ ក.ក.ជ | សមាជិក |
| ៥១ | ឯកឧត្តម យឹម លាត | អគ្គលេខាធិការរងនៃ ក.ក.ជ | សមាជិក |
| ៥២ | លោកជំទាវ ណី សុឃីម | អគ្គលេខាធិការរងនៃ ក.ក.ជ | សមាជិក |
| ៥៣ | ឯកឧត្តម កៅ មុយថង | អគ្គលេខាធិការរងនៃ ក.ក.ជ | សមាជិក |
| ៥៤ | ឯកឧត្តម ហាស់ វង់ដារ៉ា | អគ្គលេខាធិការរងនៃ ភ.១ ផ.១ | សមាជិក |

**ប្រការ ៣.**- ក្រុមការងារ ក.គ.ស.អ មានភារកិច្ចសំខាន់ៗដូចខាងក្រោមនេះ÷

**១- ការណែនាំលើផ្នែកគោលនយោបាយ**

- ធានាភាពជាម្ចាស់របស់ថ្នាក់ជាតិ និងការទទួលស្គាល់នូវតួនាទីដឹកនាំរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ លើការសម្របសម្រួលវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។
- ខិតខំស្វែងរកមតិគាំទ្រដើម្បីធានាថា រាជរដ្ឋាភិបាលបានផ្តល់អាទិភាពខ្ពស់លើវិស័យគាំពារសង្គម សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ។

- ពិនិត្យឡើងវិញនូវគោលនយោបាយ និងយុទ្ធសាស្ត្រនានាពាក់ព័ន្ធនឹងការគាំពារសង្គម សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងលិខិតបទដ្ឋានគតិយុត្តនានាដែលទាក់ទងនឹងការធ្វើឱ្យប្រសើរឡើងក្នុងការអនុវត្ត និងការផ្តល់សេវាវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។
- ផ្តល់មតិយោបល់ផ្សេងៗ ដើម្បីកែលម្អលិខិតបទដ្ឋានគតិយុត្តនានា ក្នុងការលើកទឹកចិត្តនិងបង្កើនការចូលរួមរបស់វិស័យឯកជន ក្នុងវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។
- លើកកម្ពស់ភាពសុខដុមនីយកម្មលើយុទ្ធសាស្ត្រជាតិគាំពារសង្គម សម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះនៅកម្ពុជា និងយុទ្ធសាស្ត្រជាតិសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងធានាភាពរលូននៃការអនុវត្តយុទ្ធសាស្ត្រខាងលើនេះ។
- លើកកម្ពស់ការកំណត់យន្តការនិងបែបផែននៃការសម្របសម្រួលលើការរៀបចំ និងអនុវត្តកម្មវិធីគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដូចដែលមានចែងក្នុងយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះនៅកម្ពុជា និងយុទ្ធសាស្ត្រជាតិសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលត្រូវបានកំណត់ជាអាទិភាពនៅក្នុងយុទ្ធសាស្ត្រខាងលើ។
- ធានាថាវិស័យអាទិភាពគាំពារសង្គម និងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ត្រូវបានបញ្ចូនទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ។

## ២- ការណែនាំលើផ្នែកយុទ្ធសាស្ត្រ និងថវិកា

- តាមដាននិងពិនិត្យមើលឡើងវិញលើសូចនាករនៃការតាមដានរួមគ្នា ដើម្បីឱ្យមានសង្គតភាពជាមួយវដ្តនៃផែនការ និងរបាយការណ៍របស់គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ។
- គាំទ្រការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គម និងយុទ្ធសាស្ត្រជាតិសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (២០១៤ -២០១៨) ដែលលើកកម្ពស់ការធ្វើឱ្យសម្រេចនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ២០១៥, គោលដៅផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-២០១៨) និងចក្ខុវិស័យយុទ្ធសាស្ត្រជាតិគាំពារសង្គម និងចក្ខុវិស័យយុទ្ធសាស្ត្រជាតិសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងបញ្ជាក់ពីតម្រូវការការអភិវឌ្ឍធនធានមនុស្សរបស់ស្ថាប័នពាក់ព័ន្ធនៅគ្រប់កម្រិត នៅក្នុងបរិបទនៃកំណែទម្រង់សេវាសាធារណៈ។
- កំណត់ការគាំទ្រផ្សេងៗ និងលក្ខណៈជាគំរូដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងដំណើរការអនុវត្តការផ្តល់ហិរញ្ញប្បទាន ការតាមដាន និងពិនិត្យមើលឡើងវិញនៃយុទ្ធសាស្ត្រជាតិគាំពារសង្គម និងយុទ្ធសាស្ត្រជាតិសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ។

- តាមដាននិងដឹកនាំដំណើរការរៀបចំ និងអនុវត្តផែនការសកម្មភាព នៃការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គម និងយុទ្ធសាស្ត្រជាតិសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងពិនិត្យឡើងវិញនូវដំណើរការអនុវត្តផែនការនេះ ដោយរួមបញ្ចូលទាំងសកម្មភាពសុខដុមរមនាកម្ម និងសង្គតភាពនៃការអន្តរាគមន៍ផ្សេងៗដើម្បីគាំទ្រគោលដៅយុទ្ធសាស្ត្រផែនការអភិវឌ្ឍន៍ជាតិ និងចក្ខុវិស័យនៃយុទ្ធសាស្ត្រជាតិគាំពារសង្គម និងយុទ្ធសាស្ត្រជាតិសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ។
- ផ្តល់ការណែនាំប្រឹក្សា និងសម្របសម្រួលក្នុងការគាំទ្របច្ចេកទេស សម្រាប់អភិវឌ្ឍន៍ផែនការយុទ្ធសាស្ត្រជាតិគាំពារសង្គម និងយុទ្ធសាស្ត្រសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ (២០១៤-២០១៨) ជាមួយនឹងអភិក្រមរួមគ្នាលើសមភាពយេនឌ័រ, និរន្តរភាពបរិស្ថាន, សមធម៌សង្គម, និងការផ្លាស់ប្តូរទម្លាប់ ដូចខាងក្រោមនេះ÷

  ១- ការទ្រទ្រង់ដល់ជនក្រីក្របំផុត និងជនងាយរងគ្រោះបំផុត ដែលពុំអាចមានលទ្ធភាពជួយខ្លួនឯងបានតាមរយៈសេវាកម្ម និងការឧបត្ថម្ភសង្គម។

  ២- ការកាត់បន្ថយផលប៉ះពាល់នៃហានិភ័យ ដែលអាចនឹងនាំទៅរកយុទ្ធសាស្ត្រដោះស្រាយដែលមានលក្ខណៈអវិជ្ជមាន ដោយជនក្រីក្រនិងជនងាយរងគ្រោះ។

  ៣- ការទ្រទ្រង់ដល់ជនក្រីក្រឱ្យបានឆ្លងផុតពីភាពក្រីក្រ តាមរយៈការកសាងមូលធនមនុស្ស និងការពង្រីកកាលានុប្បវត្តភាពរបស់ពួកគាត់។

  ៤- ការប្រែក្លាយជនក្រីក្រ និងជនងាយរងគ្រោះ ឱ្យក្លាយជាចលករក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមប្រកបដោយផលិតភាពខ្ពស់ និងពង្រីកទីផ្សារប្រកបដោយសមធម៌។

  ៥- លើកកម្ពស់សមភាពយេនឌ័រ និរន្តរភាពបរិស្ថាន និងគោលការណ៍សមធម៌។

  ៦- លើកកម្ពស់ការផ្លាស់ប្តូរទម្លាប់ តាមរយៈយុទ្ធសាស្ត្របញ្ជ្រាបសកម្មភាពទាំងនេះ ទៅក្នុងយុទ្ធសាស្ត្រជាតិគាំពារសង្គម និងយុទ្ធសាស្ត្រជាតិសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ។

- កំណត់ធនធានថវិកានិងគម្លាត កំណត់ដៃគូអភិវឌ្ឍដែលគាំទ្រថវិកា និងស្វែងរកមតិគាំទ្រសម្រាប់ការកើនឡើងនៃការវិភាជន៍ធនធានជាតិក្នុងការគាំទ្រ និងលើកកម្ពស់វិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

## ៣- ការកសាងសមត្ថភាព

- អភិវឌ្ឍយុទ្ធសាស្ត្រកសាងសមត្ថភាព ដោយផ្អែកលើការវាយតម្លៃពីតម្រូវការជាក់ស្តែង និងពិនិត្យពីតួនាទី-ភារកិច្ចក្នុងការអភិវឌ្ឍសមត្ថភាពនៅតាមបណ្តាអង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

- បង្កើតនិងរៀបចំសូចនាករតាមដានដែលបញ្ជាក់ពីការរីកចម្រើន ឆ្ពោះទៅការអភិវឌ្ឍសមត្ថភាពរបស់ក្រុមការងារបច្ចេកទេសវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

## ៤- ការប្រើប្រាស់ហិរញ្ញប្បទានឱ្យមានប្រសិទ្ធភាព

- នៅក្នុងបរិបទនៃសុខដុមរមនាកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា ការលើកកម្ពស់ប្រសិទ្ធភាពជំនួយ គឺរួមបញ្ចូនទាំងភាពរលូននៃការអនុវត្តគម្រោង លទ្ធផលនៃផែនការសកម្មភាព កំណត់ និងសម្របសម្រួលសកម្មភាពផ្សេងៗ។ ប្រសិទ្ធភាពនៃជំនួយ រួមមានផែនទីចង្អុលផ្លូវឆ្ពោះទៅយុទ្ធសាស្ត្រទូលំទូលាយមួយដែលដើរស្របគ្នាជាមួយនឹងយុទ្ធសាស្ត្រវិមជ្ឈការនិងវិសហមជ្ឈការ ការពិភាក្សាវិះរកយន្តការល្អនានា ដើម្បីធ្វើការនិងវិភាគរួមគ្នាលើដំណើរការគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដោយប្រើប្រាស់យន្តការសម្របសម្រួលនៃកិច្ចសហការបច្ចេកទេស តាមដាន និងប្រើប្រាស់រចនាសម្ព័ន្ធដែលមានស្រាប់ នៅក្នុងបរិបទការងារការកសាងសមត្ថភាពដ៏ទូលំទូលាយ និងអនុវត្តស្តង់ដារគោលការណ៍ប្រតិបត្តិនានា។

## ៥- របាយការណ៍និងការពិនិត្យមើលឡើងវិញ

- រៀបចំផែនការសកម្មភាពប្រចាំឆ្នាំ និងរបាយការណ៍រីកចម្រើនជូនគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ ដោយគោរពតាមសូចនាករតាមដានរួមគ្នា (JMI) និងទស្សនទាននៃភាពសុខដុមរមនាកម្ម សង្គតភាព និងលទ្ធផលផែនការសកម្មភាព។
- ផ្តល់មតិយោបល់ក្នុងរបាយការណ៍រីកចម្រើននៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងចូលរួមពង្រឹងរបាយការណ៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងចូលរួមក្នុងការពង្រឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ តាមរយៈការកំណត់បន្ថែមនូវការងារវិភាគទិន្នន័យលើវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។
- ជម្រាបទៅស្ថាប័នពាក់ព័ន្ធ ជាពិសេសវិទ្យាស្ថានជាតិស្ថិតិ ស្តីពីការបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មានលើវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។
- ពិនិត្យឡើងវិញពីតួនាទីរបស់ក្រុមការងារបច្ចេកទេសវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្រោយពីការបង្កើតឡើងរយៈពេល ០១ឆ្នាំ បើអាចធ្វើទៅបាន គឺឱ្យស្របគ្នាជាមួយប្រក្រតិទិនរបាយការណ៍របស់គណៈកម្មាធិការសម្របសម្រួលរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ។ ការណែនាំផ្សេងៗ នឹងត្រូវបានធ្វើឡើងសម្រាប់ធ្វើវិសោធនកម្មដែលទាក់ទងទៅនឹង÷
    - ទំហំនិងសមាសភាពនៃក្រុមការងារបច្ចេកទេស
    - តម្រូវការនានានៃការរៀបចំអនុក្រុមការងារបច្ចេកទេស
    - សម្របសម្រួលលើការងារផ្សេងៗទៀត

**ប្រការ ៤.-** កិច្ចដំណើរការនៃក្រុមការងារ ក.គ.ស.អ មានដូចខាងក្រោមនេះ÷

១- សមាជិកក្រុមការងារបច្ចេកទេសវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ត្រូវចូលរួមប្រជុំរៀងរាល់ ៣ខែម្តង និងករណីពិសេសណាមួយ តាមការអញ្ជើញរបស់ប្រធានក្រុមការងារ។

២- សមាជិកក្រុមការងារបច្ចេកទេសវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ត្រូវបានអញ្ជើញឱ្យចូលរួមនៅក្នុងវេទិកាគាំពារសង្គម និងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ រៀងរាល់ ២ខែម្តង។

៣- ដោយមានការឯកភាពគ្នានៅក្នុងសមាជិកនៃក្រុមការងារបច្ចេកទេសវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ប្រធានក្រុមការងារបច្ចេកទេសនេះមានសិទ្ធិបង្កើតអនុក្រុមការងារ ដើម្បីឆ្លើយតបទៅនឹងករណីចាំបាច់ណាមួយនៅក្នុងវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

៤- ក្រុមការងារបច្ចេកទេសវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ត្រូវរាយការណ៍ពីវឌ្ឍនភាពនៃវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ជូនទៅគណៈកម្មាធិការសម្របសម្រួលនៃរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍ តាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

៥- ការប្រជុំនៃក្រុមការងារបច្ចេកទេសវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ត្រូវធ្វើឡើងដោយ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី** ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ និងជាប្រធានក្រុមការងារបច្ចេកទេស ស្តីពីគាំពារសង្គម និងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងប្រធានសម្របសម្រួលភាគីដៃគូអភិវឌ្ឍលើវិស័យគាំពារសង្គម និងប្រធានសម្របសម្រួលលើវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ (Lead Facilitator of Development Partners)។ កិច្ចប្រជុំទាំងនេះ ត្រូវបានរៀបចំនិងគាំទ្រដោយលេខាធិការដ្ឋាននៃក្រុមការងារបច្ចេកទេសវិស័យគាំពារសង្គម និងសន្តិសុខស្បៀង-អាហារូបត្ថម្ភ។

**ប្រការ ៥.-** ដើម្បីសម្របសម្រួលដំណើរការប្រចាំថ្ងៃរបស់ក្រុមការងារ ក.គ.ស.អ ក្រុមការងារនេះត្រូវបង្កើតលេខាធិការដ្ឋានមួយដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយនឹងដៃគូអភិវឌ្ឍ។ សមាសភាពសមាជិកលេខាធិការដ្ឋានមាន÷

| | | |
|---|---|---|
| ១. | ឯកឧត្តម ទៀ សុខារម្យ | អគ្គលេខាធិការក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិង ជនបទ | ប្រធាន |
| ២. | ឯកឧត្តម សុខ ស៊ីទ្ស | អគ្គលេខាធិការរងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ និងជាប្រធានក្រុមអង្គភាពសម្របសម្រួលសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ | អនុប្រធាន |
| ៣. | ឯកឧត្តម សាន វឌ្ឍនា | អគ្គលេខាធិការរងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យ | អនុប្រធាន |

| | | | |
|---|---|---|---|
| | | កសិកម្មនិងជនបទ និងជាប្រធានក្រុមអង្គភាពសម្របសម្រួលគាំពារសង្គម | |
| ៤. | លោក គង់ ចន្ទី | ប្រធាននាយកដ្ឋានសាធារណៈការនៃក.ក.ជ ទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ និងប្រតិបត្តិការ | សមាជិក |
| ៥. | លោក ស៊ូ ច័ន្ទត្រីស្នា | មន្ត្រី ក.ក.ជ ទទួលបន្ទុកផ្នែករដ្ឋបាល និងទំនាក់ទំនងសាធារណៈ | សមាជិក |
| ៦. | លោក សុខ សាម៉េត | មន្ត្រី ក.ក.ជ ទទួលបន្ទុកផ្នែកគាំទ្រគោលនយោបាយ និងត្រួតពិនិត្យ-វាយតម្លៃ | សមាជិក |
| ៧. | លោក សុខ សុវឌ្ឍរា | មន្ត្រី ក.ក.ជ ទទួលបន្ទុកផ្នែកគ្រប់គ្រង និងចែកចាយព័ត៌មាន | សមាជិក |
| ៨. | មន្ត្រីបច្ចេកទេសពីប្រធានសម្របសម្រួលភាគីដៃគូអភិវឌ្ឍលើវិស័យគាំពារសង្គម និងប្រធានសម្របសម្រួលភាគីដៃគូអភិវឌ្ឍលើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ | | សមាជិក |

**លេខាធិការដ្ឋានមានភារកិច្ចដូចតទៅ÷**

១- ជំនួយការឲ្យប្រធានក្រុមការងារបច្ចេកទេសវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងការសម្របសម្រួល និងដំណើរការការងាររដ្ឋបាលប្រចាំថ្ងៃរបស់ក្រុមការងារបច្ចេកទេស។

២- រៀបចំផែនការការងារប្រចាំឆ្នាំសម្រាប់ក្រុមការងារបច្ចេកទេសវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងរបាយការណ៍រីកចម្រើនរបស់វិស័យនេះ ដើម្បីដាក់ជូនទៅសមាជិកក្រុមការងារបច្ចេកទេសពិនិត្យ និងអនុម័ត។

៣- សម្របសម្រួលកិច្ចដំណើរការប្រជុំក្រុមការងារបច្ចេកទេសវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងវេទិកាគាំពារសង្គម និងសន្តិសុខស្បៀង-អាហារូបត្ថម្ភ ដោយរួមទាំងការរៀបចំរបៀបវារៈនៃកិច្ចប្រជុំ ការចែកចាយលិខិតអញ្ជើញ ធ្វើកំណត់ហេតុអង្គប្រជុំ និងឯកសារលិខិតស្នាមរដ្ឋបាលផ្សេងៗ។

៤- រៀបចំបញ្ចប់ឯកសារគោលនយោបាយ យុទ្ធសាស្ត្រ និងឯកសារនានាដែលទាក់ទងទៅនឹងគាំពារសង្គម និងសន្តិសុខស្បៀង-អាហារូបត្ថម្ភ និងដាក់ជូនទៅកិច្ចប្រជុំក្រុមការងារបច្ចេកទេស ដើម្បីពិនិត្យនិងអនុម័ត។

៥- ត្រួតពិនិត្យលើការងារសម្របសម្រួលបច្ចេកទេសទាក់ទងទៅនឹងគាំពារសង្គម និងសន្តិសុខស្បៀង-អាហារូបត្ថម្ភ ជាមួយនឹងសមាជិកនានាមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធ, ដៃគូអភិវឌ្ឍ, អង្គការ NGO ក្នុងស្រុកនិងអន្តរជាតិ និងសង្គមស៊ីវិលនានា។

៦- សម្របសម្រួលការសិក្សា-ស្រាវជ្រាវពីវិស័យគាំពារសង្គម និងសន្តិសុខស្បៀង-អាហារូបត្ថម្ភ ដែលដឹកនាំអនុវត្តដោយសមាជិកលេខាធិការដ្ឋាននៃក្រុមការងារបច្ចេកទេសវិស័យគាំពារសង្គម និងសន្តិសុខស្បៀង-អាហារូបត្ថម្ភ។

៧- ធានានូវការធ្វើសមាហរណកម្ម និងដំណើរការវេបសាយនៃប្រព័ន្ធព័ត៌មានគាំពារសង្គម និងសន្តិសុខស្បៀង-អាហារូបត្ថម្ភ។

៨- ផ្សព្វផ្សាយរបាយការណ៍រីកចម្រើននៃវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភជូនដល់សមាជិក-សមាជិកាក្រុមការងារបច្ចេកទេសដែលជាតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធចូលរួម និងនៅក្នុងកិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ, វេទិកាគាំពារសង្គម និងសន្តិសុខស្បៀង-អាហារូបត្ថម្ភ និងប្រព័ន្ធព័ត៌មានវេបសាយនៃការគាំពារសង្គម និងសន្តិសុខស្បៀង-អាហារូបត្ថម្ភ។

៩- សម្របសម្រួលធាតុចូលពីអង្គភាពសម្របសម្រួលគាំពារសង្គម និងអង្គភាពសម្របសម្រួលសន្តិសុខស្បៀង-អាហារូបត្ថម្ភ និងអនុក្រុមការងារបច្ចេកទេសផ្សេងៗទៀត នៃវិស័យគាំពារសង្គម និងសន្តិសុខស្បៀង-អាហារូបត្ថម្ភ។

១០- ទទួលខុសត្រូវក្នុងការសម្របសម្រួល និងទំនាក់ទំនងនឹងស្ថាប័នដៃគូអភិវឌ្ឍ។

**ប្រការ ៦**.- លេខាធិការដ្ឋាននៃក.ត.ស.អ មានសិទ្ធិជ្រើសរើសទីប្រឹក្សា ឬអ្នកជំនួយការក្នុងការជួយដល់ដំណើរការប្រតិបត្តិការប្រចាំថ្ងៃរបស់លេខាធិការដ្ឋាន។

**ប្រការ ៧**.- សេចក្ដីសម្រេចទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨**.- ឯកឧត្តម លោកជំទាវ លោក លោកស្រីដូចមានចែងក្នុងប្រការ ២ និងប្រការ ៥ ត្រូវទទួលអនុវត្តសេចក្ដីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ឧបនាយករដ្ឋមន្ត្រី**

**ប្រធានក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ**

**កន្លែងទទួល**

- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ឯកឧត្តមឧបនាយករដ្ឋមន្ត្រី គាត ឈន់ អនុប្រធានទី ១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ដូចក្នុងប្រការ ២ និងប្រការ ៥

**វេជ្ជ. យឹម ឆៃលី**